JICA Cambodia Office - JICA カンボジア事務所

December 8, 2024 ·

[ពិធីបូកសរុបលទ្ធផលវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា/ Wrap-up Ceremony for In-Service Training]

------------------------------

ពិធីបូកសរុបលទ្ធផលវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការ រវាងក្រសួងសុខាភិបាល និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន (ចៃកា) បានប្រារព្ធធ្វើនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៤ នៅមន្ទីរពេទ្យកាល់ម៉ែត។ អ្នកគ្រប់គ្រងផ្នែកថែទាំចំនួន ២៤នាក់ មកពីមន្ទីរពេទ្យជាតិចំនួន ១២ នៅកម្ពុជា បានបញ្ចប់វគ្គបណ្តុះបណ្តាលទាំង៨ ដោយជោគជ័យ ដែលដឹកនាំដោយក្រសួងសុខាភិបាល និងគាំទ្រដោយគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់ ចៃកា គឺ «គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេល បម្រើការងារនៅប្រទេសកម្ពុជា»។

កម្មវិធីបណ្តុះបណ្តាលនេះ ធ្វើឡើងចាប់ពីថ្ងៃទី០៥ ខែកញ្ញា ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្នុងគោលបំណងពង្រឹងភាពជាអ្នកដឹកនាំផ្នែកថែទាំ និងលើកកម្ពស់គុណភាព នៃការថែទាំនៅកម្ពុជា។ ក្នុងរយៈពេលប្រាំបីសប្តាហ៍កន្លងមកនេះ សិក្ខាកាមបានសិក្សានូវប្រធានបទសំខាន់ៗដូចជា (១) ការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ (២) ការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ (៣) សីលធម៌ នៃការថែទាំ (៤) ការប្រាស្រ័យទាក់ទង (៥) ព័ត៌មានវិទ្យា នៃការថែទាំ (៦) ការស្រាវជ្រាវផ្នែកថែទាំ (៧) ជំនាញមូលដ្ឋាន នៃការថែទាំ (៨) ការប្រើប្រាស់ ដំណើរការ នៃការថែទាំ ។

ក្នុងពិធីនោះ តំណាងសិក្ខាកាមមកពីមន្ទីរពេទ្យនីមួយៗ បានធ្វើបទបង្ហាញអំពីសកម្មភាពនាពេលបច្ចុប្បន្ន និងរៀបរាប់ពីផែនការបណ្តុះបណ្តាលនាពេលខាងមុខនៅតាមស្ថាប័នរបស់ខ្លួន។ លោកជំទាវសាស្ត្រាចារ្យ អ៊ឹម សិទ្ធិការ្យ លោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង និងលោកសាស្ត្រាចារ្យ ជំនួយ កុយ វីរីយ៉ា នៃក្រសួងសុខាភិបាលបាន លើកទឹកចិត្តសិក្ខាកាមឱ្យអនុវត្តន៍ចំណេះដឹងដែលទទួលបានថ្មីៗក្នុងការអនុវត្តប្រចាំថ្ងៃ ចែករំលែកជាមួយក្រុម ព្រមទាំងដឹកនាំដោយគំរូ។

នាពេលខាងមុខនេះ ក្រសួងសុខាភិបាលសហការជាមួយគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេល បម្រើការងារនៅប្រទេសកម្ពុជា នឹងអនុវត្តកម្មវិធីបណ្តុះបណ្តាល នៅក្នុងខេត្តគោលដៅគឺ ខេត្តកំពង់ចាម និងបាត់ដំបង ដើម្បីជំរុញការអភិវឌ្ឍគុណភាពការថែទាំនៅទូទាំងប្រទេសកម្ពុជា។

គេហទំព័រគម្រោង (ចៃកា)៖

គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេល បម្រើការងារនៅប្រទេសកម្ពុជា

https://www.jica.go.jp/oda/project/

The Wrap-up Ceremony for In-Service Training under cooperation between the Ministry of Health and JICA was held on 3rd December 2024 at Calmette hospital. 24 nursing managers from 12 national hospitals in Cambodia successfully completed the 8 courses, which were led by the Ministry of Health and supported by JICA's technical cooperation project, "Strengthening In-Service Training System in Cambodia."

This training, conducted from 5th September to 1st November, aimed to strengthen nursing leadership and improve the quality of care in Cambodia. Over the past eight weeks, the participants have addressed crucial topics such as nursing management and leadership, quality improvement and patient safety, nursing ethics, communication, nursing informatics, nursing research, basic nursing skills, and nursing process application.

During the ceremony, a representative of participants from each hospital presented current activities and outlined the future training plans at their facilities. H.E. Prof. IM Sethikar, Asst. Prof. TOUCH Sokneang and Asst. Prof. KOY Virya from the Ministry of Health encouraged them to apply the newly acquired knowledge in daily practice, share it with their teams, and lead by example.

Looking ahead, the Ministry of Health, in collaboration with the JICA project, will implement  programs in the target provinces of Kampong Cham and Battambang, driving continued improvement in nursing care quality across Cambodia.

Project Website (JICA) :

The Project for Strengthening In-service Training System in Cambodia.

https://www.jica.go.jp/oda/project/

